ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១២០៨ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគយ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១.-**

អនុញ្ញាតឱ្យអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

សេវាសាធារណៈដែលផ្តល់ដោយអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីតម្លៃសេវា រយៈពេលអតិបរមានៃការផ្តល់សេវា និងសុពលភាព ទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ។

**ប្រការ២.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវា នូវស្តង់ដារសេវាក្នុងនោះរួមមាន ÷ តារាងកម្រងសេវាសាធារណៈ និងសំណុំឯកសារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

**ប្រការ៣.-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយនៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវពង្រឹង និងពង្រីកប្រព័ន្ធស្វ័យប្រវត្តិកម្ម សម្រាប់ការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

**ប្រការ៤.-**

រាល់ការប្រមូលចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានបត្រពីកម្រៃសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ ដែលបើកផ្តល់ដោយអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើកលែងតែការប្រមូលចំណូលដែលត្រូវបានអនុញ្ញាតឱ្យធ្វើឡើងតាមប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ។

**ប្រការ៥ .-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំ ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ។

នៅពេលអនុវត្តចំណូល ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកបត្របង់ចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ៦ .-**

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ត្រូវធ្វើរបាយការណ៍ស្ថានភាពស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។ របាយការណ៍នេះ ត្រូវចម្លងជូនអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ ដើម្បីតាមដានការអនុវត្តចំណូល។

**ប្រការ៧ .-**

កម្រងសេវាសាធារណៈ ដូចមានចែងនៅក្នុងតារាងឧបសម្ព័ន្ធដែលភ្ជាប់នឹងប្រកាសនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៨ .-**

ត្រូវបាននិរាករណ៍ប្រកាសលេខ ១១៥១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយក អគ្គាធិការ នាយកគ្រប់ប្រធាននាយកដ្ឋាន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ តទៅ។

ថ្ងៃសុក្រ ១៥កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សភាពាណិជ្ជកម្មកម្ពុជា
- ដូចប្រការ ៩
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

## តារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសលេខ ១៦០.៨ សហវ.ប្រក ចុះថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៨
## ស្តីពីការផ្តល់សេវាសាធារណៈរបស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

| ល.រ | បរិយាយ | ប្រាក់ពន្ធ | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ១ | កម្រៃស្តុកទំនិញក្នុងសន្និធិគយបណ្តោះអាសន្នហួសកាលកំណត់ (ក្នុងមួយថ្ងៃ) | 0.១% លើតម្លៃគិតពន្ធគយ | ០ រៀល | ភ្លាមៗ | សំចតលើស ៣០ថ្ងៃ នៅតាមអាកាសយានដ្ឋាន និងលើស ៤៥ថ្ងៃ នៅក្រៅអាកាសយានដ្ឋាន |
| ២ | កម្រៃទំនិញនាំចូលសម្រាប់លក់ក្នុងអគារលក់ទំនិញរួចពន្ធ (DUTY FREE SHOP) | ១០% លើតម្លៃគិតពន្ធគយ | ០ រៀល | ១-២ថ្ងៃ | |
| ៣ | កម្រៃឆ្លងកាត់ (1) ÷ | | | | |
| | - ទំនិញមួយកុងតឺន័រតូចជាង ឬស្មើ ២០ហ្វីត | ៤០០ ០០០ រៀល | ០ រៀល | ភ្លាមៗ | |
| | - ទំនិញមួយកុងតឺន័រលើសពី ២០ហ្វីត | ៤៨០ ០០០ រៀល | ០ រៀល | ភ្លាមៗ | |
| | - ទំនិញមិនផ្ទុកក្នុងកុងតឺន័រ (ក្នុងមួយម៉ែត្រគូប) | ២០ ០០០ រៀល ឬយ៉ាងតិច ២០០ ០០០ រៀល ក្នុងមួយប្រតិវេទន៍គយឆ្លងកាត់ | ០ រៀល | ភ្លាមៗ | |
| | - គោ ក្របី និងសេះរស់ (ក្នុងមួយក្បាល) | ៤០ ០០០ រៀល | ០ រៀល | ភ្លាមៗ | |
| | - ជ្រូក ចៀម និងពពែរស់ (ក្នុងមួយក្បាល) | ១០ ០០០ រៀល | ០ រៀល | ភ្លាមៗ | |
| | - សត្វស្លាប (មាន់ ទា ...) (ក្នុងមួយគីឡូក្រាម) | ១ ០០០ រៀល | ០ រៀល | ភ្លាមៗ | |
| | - ផលិតផលជលផល (ក្នុងមួយគីឡូក្រាម) | ១ ០០០ រៀល | ០ រៀល | ភ្លាមៗ | |

| ល.រ | បរិយាយ | ប្រាក់ពន្ធ | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ៤ | កម្រៃត្រួតពិនិត្យកុងតឺន័រតាមប្រព័ន្ធ TH-SCAN ÷ | | | | |
| | - មួយកុងតឺន័រក្រោម ៤០ហ្វីត | 0 រៀល | ៨០ ០០០ រៀល | ១-២ថ្ងៃ | |
| | - មួយកុងតឺន័រចាប់ពី ៤០ហ្វីត ឡើង | 0 រៀល | ១២៨ ០០០ រៀល | ១-២ថ្ងៃ | |
| ៥ | កម្រៃបែបបទគយ (Customs Processing Fee - CPF) ÷ | | | | |
| | - មួយកុងតឺន័រចាប់ពី ២០ហ្វីត ឡើង | 0 រៀល | ៦០ ០០០ រៀល | ១-២ថ្ងៃ | |
| | - មួយប្រតិវេទន៍គយផលិតផលតេលសិលា | 0 រៀល | ៦០ ០០០ រៀល | ១-២ថ្ងៃ | |
| | - មួយប្រតិវេទន៍គយទំនិញមិនផ្ទុកក្នុងកុងតឺន័រ ឬផ្ទុកក្នុងកុងតឺន័រតូចជាង ២០ហ្វីត | 0 រៀល | ៤០ ០០០ រៀល | ១-២ថ្ងៃ | |
| ៦ | កម្រៃផ្តល់លិខិតអនុញ្ញាតគយ (ក្នុងមួយឯកសារ) | 0 រៀល | 0 រៀល | ១-២ថ្ងៃ | ៣០ថ្ងៃ |
| ៧ | កម្រៃផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ (ក្នុងមួយឯកសារ) | 0 រៀល | 0 រៀល | ១-២ថ្ងៃ | ៤៥ថ្ងៃ |
| ៨ | កម្រៃផ្ទៀងផ្ទាត់វិញ្ញាបនបត្រដើមកំណើតទំនិញ (ក្នុងមួយឯកសារ) | 0 រៀល | 0 រៀល | ១-២ថ្ងៃ | ៤៥ថ្ងៃ |
| ៩ | កម្រៃអាជ្ញាប័ណ្ណសន្និធិគយបណ្តោះអាសន្ន (ក្នុងមួយឆ្នាំ) | 0 រៀល | ២០ ០០០ ០០០ រៀល | ១-២ថ្ងៃ | ១ឆ្នាំ |
| ១០ | កម្រៃអាជ្ញាប័ណ្ណភណ្ឌាគារគយមានដែនកំណត់ (ក្នុងមួយឆ្នាំ) | 0 រៀល | ១% នៃប្រាក់ពន្ធនិងអាករមធ្យមប្រចាំខែ ដែលត្រូវជាប់លើទំនិញក្នុងភណ្ឌាគារ ឬយ៉ាងតិច ២ ០០០ ០០០ រៀល | - ៩០ថ្ងៃ សម្រាប់ស្នើសុំថ្មី<br>-១-២ថ្ងៃ សម្រាប់ស្នើសុំបន្តសុពលភាព | ៣ឆ្នាំ |
| ១១ | កម្រៃអាជ្ញាប័ណ្ណដេីងសាគយ (ក្នុងមួយឆ្នាំ) | 0 រៀល | ២ ០០០ ០០០ រៀល | - ៩០ថ្ងៃ សម្រាប់ស្នើសុំថ្មី<br>-១-២ថ្ងៃ សម្រាប់ស្នើសុំបន្តសុពលភាព | ២ឆ្នាំ |

| ល.រ | បរិយាយ | ប្រាក់ពន្ធ | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ១២ | កម្រៃផ្តល់សេវាតាមវិធានបញ្ជាក់ជាមុន (Advance Ruling) (ក្នុងមួយឯកសារ) | 0 រៀល | ២00 000 រៀល | ៣0ថ្ងៃ | ៣ឆ្នាំ |
| ១៣ | កម្រៃការងារក្រៅការិយាល័យគយ (2) ÷ | | | | |
| | - កម្រៃត្រួតពិនិត្យទំនិញផ្ទុកក្នុងកុងតឺន័រ ក្នុងម៉ោងធ្វើការ (ក្នុងមួយកុងតឺន័រ) | 0 រៀល | ១0 000 រៀល | ភ្លាមៗ | |
| | - កម្រៃត្រួតពិនិត្យទំនិញផ្ទុកក្នុងកុងតឺន័រ ក្រៅម៉ោងធ្វើការ (ក្នុងមួយកុងតឺន័រ) | 0 រៀល | ២0 000 រៀល | ភ្លាមៗ | |
| | - កម្រៃត្រួតពិនិត្យទំនិញមិនផ្ទុកក្នុងកុងតឺន័រ ក្នុងម៉ោងធ្វើការ (ក្នុងមួយប្រតិវេទន៍) | 0 រៀល | ៤0 000 រៀល | ភ្លាមៗ | |
| | - កម្រៃត្រួតពិនិត្យទំនិញមិនផ្ទុកក្នុងកុងតឺន័រ ក្រៅម៉ោងធ្វើការ (ក្នុងមួយប្រតិវេទន៍) | 0 រៀល | ៨0 000 រៀល | ភ្លាមៗ | |
| | - កម្រៃអមទំនិញ (ក្នុងមួយនាក់ ក្នុងមួយថ្ងៃ) | 0 រៀល | ១00 000 រៀល | ភ្លាមៗ | |
| ១៤ | កម្រៃប័ណ្ណសម្គាល់មធ្យោបាយដឹកជញ្ជូន (ក្នុងមួយប័ណ្ណ) | 0 រៀល | ៥ 000 រៀល | ១-២ថ្ងៃ | ១ឆ្នាំ |
| ១៥ | កម្រៃសេវាប្រឹក្សាអំពីនីតិវិធីគយ | 0 រៀល | 0 រៀល | ភ្លាមៗ | |
| ១៦ | កម្រៃសេវាបង់ថ្លៃសិទ្ធិប្រឡង និងសិក្សាវគ្គជើងសាគយ | 0 រៀល | ១ 000 000 រៀល | ភ្លាមៗ | |
| ១៧ | កម្រៃសេវាចុះបញ្ជីធុរជនចូលក្នុងប្រព័ន្ធគ្រប់គ្រងហានិភ័យ (ក្នុងមួយឯកសារ) | 0 រៀល | 0 រៀល | ភ្លាមៗ | |
| ១៨ | កម្រៃសេវាកែតម្រូវ ឬធ្វើទុតិយតាបង្កាន់ដៃពន្ធ និងលតាបត្ររថយន្ត និងគ្រឿងចក្រ (ក្នុងមួយគ្រឿង) | 0 រៀល | ២00 000 រៀល | ១-២ថ្ងៃ | |
| ១៩ | កម្រៃសេវាកែតម្រូវ ឬធ្វើទុតិយតាបង្កាន់ដៃពន្ធទោចក្រយានយន្ត (ក្នុងមួយគ្រឿង) | 0 រៀល | 0 រៀល | ១-២ថ្ងៃ | |
| ២0 | កម្រៃចុះបញ្ជិកាប្រតិវេទន៍គយនាំចេញនាំចូល និងឆ្លងកាត់ (ក្នុងមួយលេខ) | 0 រៀល | ១៥ 000 រៀល | ភ្លាមៗ | |
| ២១ | កម្រៃចុះបញ្ជិកាប្រតិវេទន៍គយសង្ខេប (ក្នុងមួយលេខ) | 0 រៀល | 0 រៀល | ភ្លាមៗ | |
| ២២ | កម្រៃលិខិតរាយការណ៍គយសម្រាប់អ្នកដំណើរចូលព្រះរាជាណាចក្រកម្ពុជា (ក្នុងមួយសន្លឹក) | 0 រៀល | 0 រៀល | ភ្លាមៗ | |

| ល.រ | បរិយាយ | ប្រាក់ពន្ធ | តម្លៃសេវា | រយៈពេលអតិបរមា នៃការផ្តល់សេវា (ថ្ងៃធ្វើការ) | សុពលភាព |
|---|---|---|---|---|---|
| ២៣ | លក់លតាបត្ររថយន្ត (ក្នុងមួយលេខ) | 0 រៀល | ៤0 000 រៀល | ១-២ថ្ងៃ | |
| ២៤ | លក់ត្រាពន្ធគយ (ក្នុងមួយសន្លឹក) | 0 រៀល | ១00 រៀល | ១-២ថ្ងៃ | |
| ២៥ | លក់តែមប្រើអាករ សម្រាប់បិទលើកញ្ចប់បារី (ក្នុងមួយសន្លឹក) | 0 រៀល | ៥0 រៀល | ១-២ថ្ងៃ | |
| ២៦ | លក់លិខិតអនុញ្ញាតដឹកជញ្ជូន ឬស្តុក (ក្នុងមួយសន្លឹក) | 0 រៀល | ៥00 រៀល | ភ្លាមៗ | |
| ២៧ | លក់សៀលកុងតឺន័រ (ក្នុងមួយគ្រាប់) | 0 រៀល | ៨ 000 រៀល | ១-២ថ្ងៃ | |

<u>កំណត់សម្គាល់</u>÷

(1) ពាក្យ "កុងតឺន័រ" រាប់បញ្ចូលទាំងកុងតឺន័រភ្ជាប់នឹងរថយន្តស្រាប់ ដែលមិនអាចស្ទូចផ្ទេរចុះឡើងបាន។

(2) មន្ត្រីគយនិងរដ្ឋាករមានសមត្ថកិច្ចអមទំនិញ ត្រូវមានចំនួនសមស្រប ដោយយ៉ាងតិចមានចំនួន ០២រូប។